ដោយ ជេន ម៉ាកប្រាយដ៍
( ផ្អែកទៅលើដំណើររឿងពិត )

# យើងនឹងធ្វើកិច្ចការនេះជាមួយគ្នា

*អានី ខ្លាចមិនហ៊ានចាប់ផ្ដើមចូលរួមថ្នាក់យុវនារីទេ ។*





*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

អានី ឈ្លីក្រណាត់សំពត់របស់នាង ។ នាងព្យាយាមស្ដាប់សុន្ទរកថាទាំងឡាយ ។ ប៉ុន្តែនាងបានមានអារម្មណ៍ភ័យញាប់ញ័រ ។

ថ្ងៃនេះជាថ្ងៃដែលអានី ចាប់ផ្ដើមចូលរួមថ្នាក់យុវនារី ។ នាងនឹងទៅថ្នាក់ភ្លាមបន្ទាប់ពីការប្រជុំសាក្រាម៉ង់បានបញ្ចប់ ។ ម្នាក់ៗបានប្រាប់អានី ថានាងគួរតែរំភើបចិត្ត តែផ្ទុយទៅវិញគឺនាងភ័យខ្លាច ។

នាងមើលទៅ ថាមី ដែលជាបងស្រីរបស់នាង ។ ថាមី បាននៅថ្នាក់យុវនារីអស់រយៈពេលបីឆ្នាំហើយ ហើយនាងចូលចិត្តថ្នាក់នេះ ។ នាងតែងតែប្រាប់អានីថាវាអស្ចារ្យប៉ុណ្ណា ។ ថាមីបាននិយាយ « ឯងនឹងមានមិត្តច្រើនណាស់ » ។ « វាខុសពីថ្នាក់កុមារ ។ វាហាក់ដូចជាឯងជាមនុស្សពេញវ័យចឹង » ។

ប៉ុន្តែអានី មិនដូចជាបងស្រីរបស់នាងទេ ។ ថាមី ចូលចិត្តជួបមនុស្សថ្មី។ ហើយវាងាយស្រួលសម្រាប់នាងក្នុងការរាប់អានមិត្ត ។ អានី ស្ងៀមស្ងាត់ និងចូលចិត្តអាន ឬគូរជាជាងនិយាយជាមួយមនុស្សដទៃ ។

អានី ក៏មានមុនផងដែរ ហើយនាងមានអារម្មណ៍ខ្មាស់អៀនចំពោះរូបរាងរបស់នាង ។ នាងបានប្រើឡេលាបមុខពិសេសដែលជួយបំបាត់មុន ។ ប៉ុន្តែស្នាមក្រហមលើស្បែករបស់នាងមិនបាត់ទៅណាទេ ។

បន្ទាប់ពីការប្រជុំសាក្រាម៉ង់ អានីបានដើរអូសជើងនៅលើផ្លូវដើរ ។ នាងបានប្រាប់ម៉ាក់ និងថាមី ថា « ខ្ញុំមិនអាចចូលថ្នាក់យុវនារីបានទេនៅថ្ងៃនេះ » ។

ម៉ាក់មើលទៅបារម្ភណាស់ ។ « ម៉ាក់បានគិតថាកូនរំភើបចិត្តអំពីការទៅថ្នាក់យុវនារី ។ តើមានអ្វីកើតឡើងមែនទេ ? »

« ខ្ញុំមិនស្គាល់បងៗណាម្នាក់នោះទេ » ។ អានី បានស្ទាបមុខរបស់នាង ។ « ហើយពួកគេអាចនឹងសើចពេលពួកគេឃើញខ្ញុំ » ។

ម៉ាក់បានឱប អានី ។ « កូនត្រូវចាំថា ថាមី ក៏នឹងនៅទីនោះដែរ » ។

អានី បាននិយាយថា « កូនមិនដូចថាមីទេ » ។ នាងបានមើលទៅបងស្រីរបស់នាង ។ « បងពូកែនិយាយជាមួយគេឯង » ។

ថាមី បាននិយាយថា « បងដឹងថាវាពិបាកក្នុងការចូលរៀនថ្នាក់ថ្មី » ។ « តែយើងនឹងធ្វើកិច្ចការនេះជាមួយគ្នា ។ » បងក៏មានអារម្មណ៍ភ័យខ្លាចនៅពេលបងចាប់ផ្ដើមចូលរួមថ្នាក់យុវនារីផងដែរ » ។

អានី បានបើកភ្នែកធំៗសម្លឹងទៅថាមី ។ ថាមី មើលទៅដូចជាក្លាហានជានិច្ច ! នាងថែមទាំងប្រឡងដើម្បីចូលរួមតន្ត្រីប្រចាំសាលារបស់គាត់ ហើយបានជាប់ផ្នែកសំខាន់ទៀតផង ។ អានី មិនបានធ្វើកិច្ចការទាំងនេះទេ ។ នាងគ្រាន់តែព្យាយាមកុំឲ្យមានអ្នកចាប់អារម្មណ៍លើនាងប៉ុណ្ណោះ ។

អានី បាននិយាយថា « ប៉ុន្តែបងមិនដែលភ័យខ្លាចនោះទេ » ។

ថាមី បានញញឹម ។ « ពិតណាស់ បងភ័យខ្លាច ! បងភ័យពេលបងប្រឡងតន្ត្រី ។ តើឯងដឹងអត់ថាបងបានធ្វើអ្វី ?

អានី បានគ្រវីក្បាល ។

« បងបានអធិស្ឋាន ហើយធ្វើឲ្យអស់ពីសមត្ថភាពរបស់បង ។ ហើយបងបានជួយក្មេងៗដទៃផងដែរ ។ មើលទៅពួកគេជាច្រើននាក់ក៏ភ័យដូចបងដែរ ។ ការជួយអ្នកដទៃឲ្យមានភាពក្លាហានបានជួយឲ្យ *បង* ក្លាហាន ។

អានី បានគិតអំពីរឿងនោះ ។ តើនាងអាចធ្វើអ្វីដែល ថាមី បានធ្វើ និងជួយក្មេងស្រីៗដទៃទៀតក្នុងថ្នាក់របស់នាងកុំឲ្យភ័យខ្លាចឬទេ ?

« តើកូនគិតថាកូនអាចចូលថ្នាក់យុវនារីនៅថ្ងៃនេះទេ ? » ម៉ាក់បានសួរ ។

អានីបានដកដង្ហើមធំ ។ បន្ទាប់មកនាងបានងក់ក្បាល ។ នាងអាចធ្វើវាបាន ។

អានី និងថាមី បានដើរទៅថ្នាក់យុវនារី ។ អានី បានមើលទៅក្មេងស្រីផ្សេងទៀត ។ ពួកគេមើលទៅខ្លាចៗដូចនាងដែរ ។ ដូលី បានបង្វិលសក់ជុំវិញម្រាមដៃរបស់នាង ខណៈពេលដែលអេរីកា ខាំក្រចករបស់នាង ។

អានី បានគិតអំពីរបៀបដែលនាងអាចជួយពួកគេ ។ នាងបានដើរទៅអង្គុយក្បែរដូលី ។ « តើឯងភ័យដែរឬ ? » អានីបានខ្សឹប ។ « វាមិនអីទេ » ។

ដូលី បានញញឹម ហើយអានី បានញញឹមតបវិញ ។ ឥឡូវអានី លែងសូវភ័យហើយ ។ ប្រហែលថ្នាក់យុវនារីពិតជាអស្ចារ្យមែន ។ ●